# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**

**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៤៣៣ ព.ណ ...ភ.ប.ម

ភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១

## ជម្រាបជូន

### ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានភ្នាក់ងារអនុវត្តទាំង១៥ នៃគម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម

**កម្មវត្ថុ** : *សំណើសុំចាត់បញ្ជូនមន្ត្រីចំនួន**ពីររូប** ចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំខែវិច្ឆិកា ឆ្នាំ ២០១១ ។*

**យោង** : *លិខិតលេខ: ១១៥ សហអ របស់ DICO ចុះថ្ងៃទី ២៣ មេសា ២០១១*

**ភ្ជាប់ជូន**: *របៀបវារៈនៃកិច្ចប្រជុំ*

*តបតាមកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយស សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាតំណាងភ្នាក់ងារអនុវត្តន៍គម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP) មេត្តាជ្រាបថា: ដើម្បីជំរុញការអនុវត្តគម្រោងឲ្យមានប្រសិទ្ធិភាពនិងមានភាពរលូន នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) នឹងរៀបចំ **កិច្ចប្រជុំប្រចាំខែវិច្ឆិកា រវាង DICO និង ភ្នាក់ងារអនុវត្តគម្រោង ( Implementing Agencies ) ទាំងអស់ ក្នុងគោលបំណងស្វែងយល់អំពីការធ្វើផែនការការងារ ផែនការថវិកា សំរាប់ឆ្នាំ ២០១២ និង បញ្ហានានា ដែលកើតមានឡើងក្នុងការអនុវត្តគម្រោង** ។*

*ដើម្បីធានានូវការអនុវត្តគម្រោងមានប្រសិទ្ធិភាពខ្ពស់ប្រកបដោយតម្លាភាព និងបានទាន់ពេលវេលា ខ្ញុំសូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាប្រធានភ្នាក់ងារអនុវត្តន៍គម្រោង មេត្តាចាត់បញ្ជូនមន្ត្រីជាថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលមកចូលរួមក្នុងកិច្ចប្រជុំខាងលើដែលនឹងប្រព្រឹត្តិទៅ**នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ វេលាម៉ោង ១៤:៣០ នាទី នៅសាលប្រជុំក្រសួងពាណិជ្ជកម្ម** ។*

*សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។/.*

ជ. **ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុរដ្ឋលេខាធិការ**

**ឌិត-ទីណា**

**ចម្លងជូន:**

. ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
. ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការ
. ឯកឧត្តម ឌិត ទីណា អនុរដ្ឋលេខាធិការ
. ឯកឧត្តម សុខ សុភ័ក្ត្រ អគ្គនាយកពាណិជ្ជកម្ម
. ឯកសារ កាលប្បវត្តិ

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារ:(៨៥៥) -២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*